**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៥៨ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកំណត់ផ្ទៃដីទំហំ ១១ ១៧៧ (ដប់មួយពាន់ មួយរយចិតសិបប្រាំពីរ) ហិកតា ស្ថិតក្នុងឧទ្យានជាតិ ព្រះមុនីវង្ស "បូកគោ" ជាតំបន់ប្រើប្រាស់ដោយចីរភាព ក្នុងភូមិសាស្ត្រខេត្តកំពត និងខេត្តព្រះសីហនុ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ ._**

កំណត់ផ្ទៃដីទំហំ ១១ ១៧៧ (ដប់មួយពាន់ មួយរយចិតសិបប្រាំពីរ) ហិកតា ស្ថិតក្នុងឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ជាតំបន់ប្រើប្រាស់ដោយចីរភាព ក្នុងភូមិសាស្ត្រខេត្តកំពត និងខេត្តព្រះសីហនុ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងចុះបញ្ជីជូនក្រសួងបរិស្ថាន។

**មាត្រា២ ._**

អនុញ្ញាតជូនក្រុមហ៊ុន សុខា អូតែល ធ្វើការអភិវឌ្ឍទីតាំងដីដូចមានចែងក្នុងមាត្រា១ ខាងលើ ស្របតាមកិច្ចសន្យាស្តីពីការជួលដីសម្រាប់គម្រោងអភិវឌ្ឍន៍ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ ដោយអភិរក្សទីតាំងដែលមានគុណតម្លៃជីវៈចម្រុះ តំបន់ដែលមានអេកូឡូស៊ីផុយស្រួយ តំបន់ទីជម្រាល និងផ្ទៃរងទឹកភ្លៀង និងរបៀងសត្វព្រៃនិងផលប៉ះពាល់ និងត្រូវអនុលោមតាមប្លង់គោលប្រើប្រាស់គម្រោងអភិវឌ្ឍន៍ក្រុងបូកគោចក្ខុវិស័យឆ្នាំ២០៣៥ ដែលរាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យប្រើប្រាស់តាមរយៈអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។

**មាត្រា៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពត និងខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧ កើត ខែ ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ផែនទីបង្ហាញក្បាលដីចំនួន៥ ទីតាំង ទំហំ ១១ ១៧៧ ហិកតា ដែលក្រុមហ៊ុន សុខា អូតែល ស្នើសុំពង្រីកបន្ថែមសម្រាប់ គម្រោងអភិវឌ្ឍន៍នៅឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " ស្ថិតនៅភូមិសាស្ត្រ ក្រុងបូកគោ ខេត្តកំពត និងស្រុកព្រៃនប់ ខេត្តព្រះសីហនុ**




**តារាងនិយាមកាព្រំដី**

Projection UTM Zone 48N

Datum WGS 1984

| Name | ID | E | N |
|---|---|---|---|
| A | 1 | 389864.735 | 1183195.306 |
| A | 2 | 392260.947 | 1181297.699 |
| A | 3 | 391884.735 | 1180373.306 |
| A | 4 | 391053.735 | 1179958.306 |
| A | 5 | 388532.735 | 1182293.306 |
| 6 | 6 | 389235.981 | 1184329.155 |
| 7 | 7 | 384176.768 | 1193452.576 |
| 8 | 8 | 389613.410 | 1196862.874 |
| 9 | 9 | 392530.623 | 1191959.066 |
| B | 10 | 390822.164 | 1190259.754 |
| B | 11 | 393373.250 | 1188132.173 |
| B | 12 | 392283.273 | 1186242.590 |
| B | 13 | 388822.871 | 1189128.532 |
| B | 14 | 388380.262 | 1188692.282 |
| B | 15 | 389145.128 | 1186563.969 |
| C | 16 | 382602.735 | 1199366.306 |
| C | 17 | 384252.721 | 1200401.661 |
| C | 18 | 385467.857 | 1199465.168 |
| C | 19 | 386392.786 | 1199538.576 |
| C | 20 | 386727.276 | 1198152.833 |
| C | 21 | 385147.032 | 1197712.458 |
| C | 22 | 384080.441 | 1198598.337 |
| C | 23 | 383552.270 | 1198967.751 |
| D | 24 | 387620.735 | 1212073.306 |
| D | 25 | 387833.321 | 1210465.946 |
| D | 26 | 389246.199 | 1210029.383 |
| D | 27 | 390075.361 | 1210188.921 |
| D | 28 | 390373.326 | 1208640.317 |
| D | 29 | 390525.474 | 1207849.565 |
| D | 30 | 389580.106 | 1206714.658 |
| D | 31 | 388411.078 | 1207416.901 |
| D | 32 | 387868.510 | 1208032.142 |
| D | 33 | 387201.255 | 1209336.309 |
| D | 34 | 387285.632 | 1209735.694 |
| D | 35 | 387094.962 | 1211105.466 |
| D | 36 | 386260.516 | 1212428.578 |
| D | 37 | 386214.068 | 1212823.388 |
| D | 38 | 386423.735 | 1213445.306 |
| E | 39 | 389551.735 | 1212456.306 |
| E | 40 | 389375.735 | 1214355.306 |
| E | 41 | 390652.735 | 1215392.306 |
| E | 42 | 390747.735 | 1215919.306 |
| E | 43 | 389902.735 | 1217291.306 |
| E | 44 | 389867.065 | 1217847.215 |
| E | 45 | 389869.000 | 1217849.291 |
| E | 46 | 389607.782 | 1221896.285 |
| E | 47 | 391340.160 | 1223236.031 |
| E | 48 | 392754.000 | 1222226.000 |
| E | 49 | 393327.000 | 1220808.000 |
| E | 50 | 393164.000 | 1218929.000 |
| E | 51 | 394421.000 | 1217620.000 |
| E | 52 | 393182.694 | 1217189.589 |
| E | 53 | 394411.978 | 1211472.633 |
| E | 54 | 392984.850 | 1210723.901 |
| E | 55 | 391268.722 | 1211710.758 |
| E | 56 | 392721.287 | 1212417.197 |
| E | 57 | 392437.311 | 1214180.837 |
| E | 58 | 392046.599 | 1213909.450 |

ផែនទីនិងតារាងនិយាមកាឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ១៤៨អនក្រ.បក ចុះថ្ងៃទី...៩....ខែសីហា..ឆ្នាំ២០២២




តារាងនិយាមកាព្រំដី

Projection UTM Zone 48N

Datum WGS 1984

| Name | ID | E | N |
|---|---|---|---|
| A | 1 | 389864.735 | 1183195.306 |
| A | 2 | 392260.947 | 1181297.699 |
| A | 3 | 391884.735 | 1180373.306 |
| A | 4 | 391053.735 | 1179958.306 |
| A | 5 | 388532.735 | 1182293.306 |
| 6 | 6 | 389235.981 | 1184329.155 |
| 7 | 7 | 384176.768 | 1193452.576 |
| 8 | 8 | 389613.410 | 1196862.874 |
| 9 | 9 | 392530.623 | 1191959.066 |
| B | 10 | 390822.164 | 1190259.754 |
| B | 11 | 393373.250 | 1188132.173 |
| B | 12 | 392283.273 | 1186242.590 |
| B | 13 | 388822.871 | 1189128.532 |
| B | 14 | 388380.262 | 1188692.282 |
| B | 15 | 389145.128 | 1186563.969 |
| C | 16 | 382602.735 | 1199366.306 |
| C | 17 | 384252.721 | 1200401.661 |
| C | 18 | 385467.857 | 1199465.168 |
| C | 19 | 386392.786 | 1199538.576 |
| C | 20 | 386727.276 | 1198152.833 |
| C | 21 | 385147.032 | 1197712.458 |
| C | 22 | 384080.441 | 1198598.337 |
| C | 23 | 383552.270 | 1198967.751 |
| D | 24 | 387620.735 | 1212073.306 |
| D | 25 | 387833.321 | 1210465.946 |
| D | 26 | 389246.199 | 1210029.383 |
| D | 27 | 390075.361 | 1210188.921 |
| D | 28 | 390373.326 | 1208640.317 |
| D | 29 | 390525.474 | 1207849.565 |
| D | 30 | 389580.106 | 1206714.658 |
| D | 31 | 388411.078 | 1207416.901 |
| D | 32 | 387868.510 | 1208032.142 |
| D | 33 | 387201.255 | 1209336.309 |
| D | 34 | 387285.632 | 1209735.694 |
| D | 35 | 387094.962 | 1211105.466 |
| D | 36 | 386260.516 | 1212428.578 |
| D | 37 | 386214.068 | 1212823.388 |
| D | 38 | 386423.735 | 1213445.306 |
| E | 39 | 389551.735 | 1212456.306 |
| E | 40 | 389375.735 | 1214355.306 |
| E | 41 | 390652.735 | 1215392.306 |
| E | 42 | 390747.735 | 1215919.306 |
| E | 43 | 389902.735 | 1217291.306 |
| E | 44 | 389867.065 | 1217847.215 |
| E | 45 | 389869.000 | 1217849.291 |
| E | 46 | 389607.782 | 1221896.285 |
| E | 47 | 391340.160 | 1223236.031 |
| E | 48 | 392754.000 | 1222226.000 |
| E | 49 | 393327.000 | 1220808.000 |
| E | 50 | 393164.000 | 1218929.000 |
| E | 51 | 394421.000 | 1217620.000 |
| E | 52 | 393182.694 | 1217189.589 |
| E | 53 | 394411.978 | 1211472.633 |
| E | 54 | 392984.850 | 1210723.901 |
| E | 55 | 391268.722 | 1211710.758 |
| E | 56 | 392721.287 | 1212417.197 |
| E | 57 | 392437.311 | 1214180.837 |
| E | 58 | 392046.599 | 1213909.450 |